**ស្ថានទូតអូស្ត្រាលី ភ្នំពេញ**

**សេចក្តីប្រកាសព័ត៌មាន**

**ថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៩**

# ពិធីសម្ពោធកម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលី ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌

ថ្ងៃនេះ លោកជំទាវឯកអគ្គរាជទូតអូស្ត្រាលី Angela Corcoran នឹងបើកសម្ពោធជាផ្លូវការនូវកម្មវិធីថ្មីមួយដើម្បីជួយដល់ជនដែលមានពិការភាពឬស្ត្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅកម្ពុជា ដើម្បីទទួលបានសេវាកម្មដែលពួកគេត្រូវការ។

កម្មវិធីកិច្ចសហប្រតិបត្តិការកម្ពុជា-អូស្ត្រាលី ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តភាព និងសមធម៌ (ACCESS) រយៈពេលបីឆ្នាំ (២០១៨ ដល់ ២០២១) ដោយមានមូលនិធិសរុបចំនួន ១៥លានដុល្លាអូស្ត្រាលី គឺជាគំនិតផ្តួចផ្តើមរបស់ប្រទេសអូស្ត្រាលីដើម្បីលើកកម្ពស់សេវាប្រកបដោយនិរន្តរភាព គុណភាព និងបរិយាបន្នសម្រាប់ជនមានពិការភាព និងស្ត្រីដែលរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

លោកជំទាវ Angela Corcoran ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំកម្ពុជាបានមានប្រសាសន៍ថា៖ «កម្មវិធី ACCESS ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការគាំទ្រការគោរពសិទ្ធិមនុស្ស សមភាពយេនឌ័រ និងការអភិវឌ្ឍប្រកបដោយបរិយាបន្នសម្រាប់ជនមានពិការភាពនៅក្នុងតំបន់របស់យើង»។

លោកជំទាវឯកអគ្គរាជទូតមានប្រសាសន៍បន្ថែមទៀតថា៖ «ស្ត្រីក្នុងភាពជាអ្នកដឹកនាំ សមភាពយេនឌ័រ  បរិយាបន្នសម្រាប់ជនមានពិការភាព គឺជាស្នូលនៃការកាត់បន្ថយភាពក្រីក្រនិងកំណើនសេដ្ឋកិច្ច»។

កម្មវិធី ACCESS នឹងអនុវត្តការងារជាមួយរាជរដ្ឋាភិបាលកម្ពុជា សង្គមស៊ីវិល និងវិស័យឯកជន ព្រមទាំងអ្នកផ្តល់សេវាកម្មនានាក្នុងការធ្វើផែនការ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព និងធ្វើឲ្យប្រសើរឡើងដល់ការផ្តល់សេវាដល់ជនមានពិការភាព និងស្រ្តីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ប្រកបដោយនិរន្តរភាព។

ថ្ងៃនេះ យើងនឹងប្រកាសបើកឲ្យមានការដាក់សំណើសុំមូលនិធិសម្រាប់អង្គការនានា ដែលមានចំណាប់អារម្មណ៍ចង់ចូលរួមអនុវត្តគម្រោងជាមួយកម្មវិធីACCESS។

លោកជំទាវឯកអគ្គរាជទូត ដោយមានការចូលរួមដោយឯកឧត្តមបណ្ឌិត វង សូត រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ និងលោកជំទាវវេជ្ជបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី នឹងប្រារព្ធពិធីសម្ពោធកម្មវិធីACCESSជាផ្លូវការនាថ្ងៃនេះ។

ព័ត៌មានបន្ថែមនៃកម្មវិធីACCESS សូមចូលទៅកាន់៖ www.accesscambodia.org

ព័ត៌មានបន្ថែម៖ Australian.Embassy.Cambodia@dfat.gov.au